**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០៥២-សណ.១៧ អអក

ភ្នំពេញ, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១៧

# សេចក្តីជូនដំណឹងរបស់អាជ្ញាធរអគ្គិសនីកម្ពុជា

## ស្តីពីការពិគ្រោះយោបល់សាធារណៈក្នុងការកែសម្រួលអាជ្ញាបណ្ណរបស់លោក វង្ស សំបូរ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំប្រម៉ោយ និងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

អាជ្ញាធរអគ្គិសនីកម្ពុជា មានកិត្តិយសសូមជម្រាបជូនសាធារណជននៅក្នុងឃុំប្រម៉ោយ និងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ឲ្យបានជ្រាបថា អាជ្ញាធរអគ្គិសនីកម្ពុជាបានចេញអាជ្ញាបណ្ណរួម(ផលិតកម្ម និងចែកចាយ) ឲ្យលោក វង្ស សំបូរ សម្រាប់ធ្វើសេវាកម្មអគ្គិសនីនៅឃុំប្រម៉ោយ និងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ។ ពេលនេះ អាជ្ញាធរអគ្គិសនីកម្ពុជាបានអនុញ្ញាតឲ្យលោក វង្ស សំបូរ ទិញអគ្គិសនីពីអគ្គិសនីកម្ពុជា មកជំនួសឲ្យការផលិតដោយម៉ាស៊ីនផ្ទាល់ខ្លួន ។ ដោយឃើញថា នៅតំបន់ធ្វើសេវាកម្មអគ្គិសនីរបស់លោក វង្ស សំបូរ លែងត្រូវការមធ្យោបាយផលិតទៀតហើយ ដូច្នេះ អាជ្ញាធរអគ្គិសនីកម្ពុជាគ្រោងចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណរបស់លោក វង្ស សំបូរ ដោយប្តូរប្រភេទអាជ្ញាបណ្ណ ពីអាជ្ញាបណ្ណរួមមកអាជ្ញាបណ្ណចែកចាយវិញ តាមខ្លឹមសារដូចមានជូនភ្ជាប់មកជាមួយនេះ ។ យោងតាមនីតិវិធីរបស់អាជ្ញាធរអគ្គិសនីកម្ពុជាក្នុងការកែសម្រួលអាជ្ញាបណ្ណ អាជ្ញាធរមូលដ្ឋាន ស្ថាប័ននានាដែលពាក់ព័ន្ធ និងសាធារណជន មានសិទ្ធិពិនិត្យផ្តល់យោបល់ និងអនុសាសន៍ឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាលើខ្លឹមសារនៃសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណដែលគ្រោងនឹងចេញនេះ ។

អាជ្ញាធរអគ្គិសនីកម្ពុជានឹងតម្កល់ទុកសេចក្តីព្រាងសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណនៅ ........................ .................................................................................................... សម្រាប់សាធារណជនពិនិត្យ ។

អាស្រ័យហេតុនេះ សូមសាធារណជននៅក្នុងឃុំប្រម៉ោយ និងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់ ដែលមានចំណាប់អារម្មណ៍ចង់ពិនិត្យ ឬផ្តល់យោបល់លើខ្លឹមសារនៃការចេញសេចក្តីសម្រេចកែសម្រួលអាជ្ញាបណ្ណឲ្យលោក វង្ស សំបូរ អាចអញ្ជើញមកទីកន្លែងខាងលើដើម្បីពិនិត្យឯកសារពាក់ព័ន្ធ និងផ្តល់មតិឲ្យអាជ្ញាធរអគ្គិសនីកម្ពុជាចាប់ពីថ្ងៃប្រកាសជូនដំណឹងនេះ រហូតដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ។ អាជ្ញាធរអគ្គិសនីកម្ពុជាសូមបញ្ជាក់ជូនថា " **អាជ្ញាធរអគ្គិសនីកម្ពុជានឹងធ្វើការពិចារណាតែចំពោះមតិយោបល់ណា ដែលមានបង្ហាញនូវហេតុផលយ៉ាងច្បាស់លាស់ប៉ុណ្ណោះ** " ។

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

បណ្ឌិត.ឌី ឆវិន្ទ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
**ទូរស័ព្ទ** : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ **ទូរសារ** : ០២៣ ២១៤ ១៤៤, **អ៊ីម៉ែល** : admin@eac.gov.kh ; Website : www.eac.gov.kh

សេចក្តីព្រាង

អាជ្ញាធរអគ្គិសនីកម្ពុជា
ELECTRICITY AUTHORITY OF CAMBODIA

ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
ELECTRICITY LAW OF THE KINGDOM OF CAMBODIA

# សេចក្តីសម្រេចកែសម្រួលលើកទី៣
# លើឯកសារអាជ្ញាបណ្ណលេខ ២៨១ ឯអ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១០ សម្រាប់លោក វង្ស សំបូរ ធ្វើសេវាកម្មអគ្គិសនី នៅឃុំប្រម៉ោយ និងឃុំអន្លង់រាប ស្រុកវាលវែង ខេត្តពោធិ៍សាត់

## សម្រាប់ការប្តូរប្រភេទអាជ្ញាបណ្ណពីអាជ្ញាបណ្ណរួម មកអាជ្ញាបណ្ណចែកចាយ

# DECISION ON THE THIRD REVISION

# TO THE LICENSE DOCUMENT No.281 LD DATED MAY 18, 2010 OF MR. VONG SOMBO FOR PROVIDING ELECTRIC POWER SERVICE AT KHUM PRAMOUY AND KHUM ANLONG REAP, VEAL VENG DISTRICT, PURSAT PROVINCE

## FOR CHANGING THE TYPE OF LICENSE
## FROM CONSOLIDATED LICENSE TO DISTRIBUTION LICENSE

ថ្ងៃទី ខែ ឆ្នាំ២០១៧

., 2017